**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ១០៣ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកែសម្រួលមាត្រា៤ មាត្រា៩ មាត្រា១១ មាត្រា១២ មាត្រា១៧ និងតារាង ឧបសម្ព័ន្ធ២ ឧបសម្ព័ន្ធ៣ ឧបសម្ព័ន្ធ៤ និងឧបសម្ព័ន្ធ៥ នៃអនុក្រឹត្យលេខ២៧ អនក្រ.បក ចុះថ្ងៃទី៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការត្រួតពិនិត្យការបំពុលទឹក

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាននិងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ១៣៥ អនក្រ.បក ចុះថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ២៧ អនក្រ.បក ចុះថ្ងៃទី៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការត្រួតពិនិត្យការបំពុលទឹក
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន

## សម្រេច

**មាត្រាមួយ .-**

មាត្រា៤ មាត្រា៩ មាត្រា១១ មាត្រា១២ មាត្រា១៧ និងតារាងឧបសម្ព័ន្ធ២ ឧបសម្ព័ន្ធ៣ ឧបសម្ព័ន្ធ៤ និង ឧបសម្ព័ន្ធ៥ នៃអនុក្រឹត្យលេខ២៧ អនក្រ.បក ចុះថ្ងៃទី៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការត្រួតពិនិត្យការបំពុលទឹក ត្រូវបានធ្វើការកែសម្រួល ដូចតទៅៈ

**មាត្រា៨.-ថ្មី**

ការបញ្ចេញសំណល់រាវពីប្រភពបំពុលនានា ត្រូវអនុលោមតាមកម្រិតកំណត់ស្តង់ដានៃការបញ្ចេញសំណល់រាវដែលមានចែងក្នុងតារាងឧបសម្ព័ន្ធ២ នៃអនុក្រឹត្យនេះ។

**មាត្រា៩.-ថ្មី**

ហាមឃាត់ជាដាច់ខាត៖

ក-ការបញ្ចេញទឹកកខ្វក់ពីប្រភពបំពុលចូលទៅក្នុងបណ្តាញលូសាធារណៈឬតំបន់ទឹកសាធារណៈ ដោយមិនបានធ្វើប្រព្រឹត្តកម្មសម្អាតឬមិនឆ្លើយតបស្តង់ដាបញ្ចេញដែលមានចែងក្នុងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

ខ-ការបញ្ចេញសំណល់រាវមិនឆ្លងកាត់អាងប្រព្រឹត្តកម្មសម្អាតសំណល់រាវ។

គ-ការបង្កប់លូឬការបូមបញ្ចេញសំណល់រាវវាងមិនឆ្លងកាត់អាងប្រព្រឹត្តកម្មសម្អាតសំណល់រាវ។

ឃ-ការមិនដាក់ឱ្យដំណើរការអាងប្រព្រឹត្តកម្មសម្អាតសំណល់រាវឬដំណើរការអាងប្រព្រឹត្តកម្មសម្អាតសំណល់រាវមិនត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស ដែលបានកំណត់នៅក្នុងលិខិតអនុញ្ញាតរបស់ក្រសួង ស្ថាប័នមានសមត្ថកិច្ច។

**មាត្រា១១.-ថ្មី**

ប្រភពបំពុលដែលតម្រូវឱ្យសុំការអនុញ្ញាតពីក្រសួងបរិស្ថាន មុននឹងធ្វើការបញ្ចេញចោលឬដឹកជញ្ជូនចេញនូវសំណល់រាវរបស់ម្ចាស់សំណើទៅកន្លែងដទៃទៀត ដូចមានចែងនៅក្នុងតារាងឧបសម្ព័ន្ធ៣ នៃអនុក្រឹត្យនេះ មានបីកម្រិតដូចខាងក្រោម៖

ក-ប្រភពបំពុលកម្រិតទី១ តម្រូវឱ្យមានការសុំអនុញ្ញាតពីក្រសួងបរិស្ថាន ក្នុងករណីដែលបរិមាណសំណល់រាវរបស់ប្រភពបំពុលនោះមានចំនួនច្រើនជាង៤០ម៉ែត្រគូបក្នុងមួយថ្ងៃ ដោយពុំគិតបញ្ចូលនូវបរិមាណទឹកដែលប្រើប្រាស់សម្រាប់ប្រព័ន្ធត្រជាក់គ្រឿងចក្រ។

ខ-ប្រភពបំពុលកម្រិតទី២ តម្រូវឱ្យមានការសុំអនុញ្ញាតពីក្រសួងបរិស្ថាន ក្នុងករណីដែលបរិមាណសំណល់រាវរបស់ប្រភពបំពុលនោះមានចំនួនច្រើនជាង២០ម៉ែត្រគូបក្នុងមួយថ្ងៃ ដោយពុំគិតបញ្ចូលនូវបរិមាណទឹកដែលប្រើប្រាស់សម្រាប់ប្រព័ន្ធត្រជាក់គ្រឿងចក្រ។

គ-ប្រភពបំពុលកម្រិតទី៣ តម្រូវឱ្យមានការសុំការអនុញ្ញាតពីក្រសួងបរិស្ថាន ទោះបីក្នុងបរិមាណណាក៏ដោយ។

នីតិវិធីនៃការស្នើសុំការអនុញ្ញាតធ្វើការបញ្ចេញចោលឬដឹកជញ្ជូនចេញនូវសំណល់រាវរបស់ម្ចាស់សំណើទៅកន្លែងដទៃទៀត ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថានស្តីពីនីតិវិធីនៃការស្នើសុំការអនុញ្ញាតធ្វើការបញ្ចេញចោលឬដឹកជញ្ជូនចេញនូវសំណល់រាវ។

**មាត្រា១២.-ថ្មី**

ការស្នើសុំបញ្ចេញចោលនូវសំណល់រាវពីប្រភពបំពុលអាចទទួលបានការអនុញ្ញាត លុះត្រាតែ៖

ក-មានការបំពាក់បរិក្ខារប្រព្រឹត្តកម្មសម្អាតសំណល់រាវ និងបញ្ចេញសំណល់រាវបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស និងស្ថិតក្នុងស្ថានភាពដំណើរការជាប្រក្រតី។

ខ- ការបញ្ចេញសំណល់រាវ គឺបានឆ្លើយតបនឹងស្តង់ដានៃការបញ្ចេញសំណល់រាវ។

ការស្នើសុំដឹកជញ្ជូនចេញនូវសំណល់រាវពីប្រភពបំពុលអាចទទួលបានការអនុញ្ញាត លុះត្រាតែ៖

ក-មានការបញ្ជាក់ច្បាស់ពីគោលបំណងនៃការស្នើសុំដឹកជញ្ជូនចេញនូវសំណល់រាវ និងមធ្យោបាយគ្រប់គ្រងសំណល់របស់ទីតាំងដែលទទួលសំណល់រាវ។

ខ-បានបំពេញលក្ខខណ្ឌតម្រូវដូចមានកំណត់នៅក្នុងប្រកាសរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថានស្តីពីនីតិវិធីនៃការស្នើសុំការអនុញ្ញាតធ្វើការបញ្ចេញចោលឬដឹកជញ្ជូនចេញនូវសំណល់រាវ។

**មាត្រា១៧.- ថ្មី**

លិខិតអនុញ្ញាតបញ្ចេញចោលឬដឹកជញ្ជូនចេញនូវសំណល់រាវ ត្រូវព្យួរជាបណ្ដោះអាសន្នឬដកហូតជាស្ថាពរ ក្នុងករណីណាមួយដូចខាងក្រោម៖

ក-មិនបានអនុវត្តត្រឹមត្រូវតាមស្តង់ដានៃការបញ្ចេញសំណល់រាវ។

ខ-ខកខានមិនបានអនុវត្តលក្ខខណ្ឌតម្រូវ ដែលមានកំណត់ក្នុងលិខិតអនុញ្ញាត។

គ-កើតមានករណីការបំពុលបរិស្ថានឬការបង្កគ្រោះថ្នាក់ដល់សុខភាពបណ្ដាលមកពីសកម្មភាពគ្រប់គ្រងសំណល់រាវមានការខ្វះចន្លោះឬការធ្វេសប្រហែស។

**មាត្រាពីរ.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រាបី.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ៥ រោច ខែបឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែមិថុនា ឆ្នាំ២០២១

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្ដីគោរពជម្រាបជូន

សម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងបរិស្ថាន**

**សាយ សំអាល់**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្ដេច ឯកឧត្ដម លោកជំទាវឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រាបី
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ

## តារាងឧបសម្ព័ន្ធ២
## កម្រិតកំណត់ស្តង់ដានៃការបញ្ចេញសំណល់រាវ

| ល.រ | ប៉ារ៉ាម៉ែត្រ | ខ្នាត | បរិមាណសារធាតុបំពុលដែលអនុញ្ញាតឱ្យបញ្ចេញចូល | | |
|---|---|---|---|---|---|
| | | | តំបន់ទឹកសាធារណៈប្រភេទទី១ | តំបន់ទឹកសាធារណៈប្រភេទទី២ | បណ្តាញលូភ្ជាប់ទៅស្ថានីយប្រព្រឹត្តកម្មទឹកកខ្វក់រួម |
| ១ | សីតុណ្ហភាព[១] (T) | °C | <៤០ | <៤០ | <៤៥ |
| ២ | ពណ៌ (Color) | mg Pt/l | <៥០ | <១៥០ | <៣០០ |
| ៣ | សារធាតុរឹងអណ្តែតក្នុងទឹក (TSS) | mg/l | <៥០ | <១០០ | <២០០ |
| ៤ | pH | | ៦-៩ | ៥,៥-៩ | ៥-៩ |
| ៥ | $BOD_5$ | mg/l | <៣០ | <៦០ | <២០០ |
| ៦ | COD ($Cr_2O_7^{-2}$) | mg/l | <៦០ | <១២០ | <៣០០ |
| ៧ | ប្រេងឬខ្លាញ់ (Oil & grease) | mg/l | <៥ | <១០ | <៣០ |
| ៨ | សាប៊ូ (Detergent) | mg/l | <៥ | <១០ | <៣០ |
| ៩ | អាម៉ូញាក់ ($NH_3$- as N) | mg/l | <៧ | <១០ | <៣០ |
| ១០ | នីត្រាត ($NO_3^{-1}$ as N) | mg/l | <១០ | <២០ | - |
| ១១ | ក្លរក្នុងទំរង់សេរី ($Cl_2$) | mg/l | <១ | <២ | - |
| ១២ | ក្លរជាអ៊ីយ៉ុង ($Cl^-$) | mg/l | <៥០០ | <១០០០ | - |
| ១៣ | ផូស្វាត ($PO_4^{-3}$) | mg/l | <២ | <៥ | - |
| ១៤ | អាសូតសរុប (T-N) | mg/l | <២០ | <៤០ | - |
| ១៥ | ផូស្វ័រ (T-P) | mg/l | <៤ | <៦ | - |
| ១៦ | អ៊ីដ្រូសែនស៊ុលហ្វីត ($H_2S$) | mg/l | <០,២ | <០,៥ | <១ |
| ១៧ | ម៉ង់កាណែស (Mn) | mg/l | <១ | <៣ | <៥ |
| ១៨ | បរ (B) | mg/l | <១ | <២,៥ | <៥ |
| ១៩ | បារ្យ៉ូម (Ba) | mg/l | <២ | <៥ | <៧ |
| ២០ | ស្យានីតក្នុងទំរង់សេរី ($CN^{-1}$) | mg/l | <០,១ | <០,២ | <១ |
| ២១ | ស្យានីតសរុប (CN) | mg/l | <១ | <១,៥ | <២ |
| ២២ | អាសេនិច (As) | mg/l | <០,០៥ | <០,១ | <០,៥ |
| ២៣ | ដែក (Fe) | mg/l | <១ | <៥ | <២០ |
| ២៤ | សំណ (Pb) | mg/l | <០,១ | <០,៣ | <០,៥ |
| ២៥ | ស័ង្កសី (Zn) | mg/l | <២ | <៥ | <១០ |
| ២៦ | ទង់ដែង (Cu) | mg/l | <១ | <២ | <៥ |
| ២៧ | ក្រូម ($Cr^{+6}$) | mg/l | <០,០៥ | <០,១ | <០,៥ |
| ២៨ | កាត់ម្យូម (Cd) | mg/l | <០,០៥ | <០,១ | <០,៥ |
| ២៩ | នីកែល (Ni) | mg/l | <០,២ | <០,៥ | <២ |
| ៣០ | សេលេញ៉ូម (Se) | mg/l | <០,០២ | <០,៥ | <២ |

| | | | | | |
|---|---|---|---|---|---|
| ៣១ | បារ៉ត (Hg) | mg/l | <0,00៥ | <0,0១ | <0,0៥ |
| ៣២ | ផេណុល ($C_6H_6O$) | mg/l | <0,៥ | <១ | <៥ |

**កំណត់សម្គាល់៖**

**តំបន់ទឹកសាធារណៈប្រភេទទី១៖** សំដៅដល់ប្រភពទឹកបិទមានជាអាទិ៍ ស្រះ ត្រពាំង បឹង ទីទំនាប រួមបញ្ចូលទាំង ប្រឡាយទឹក អូរ ព្រែក ស្ទឹង ដែលមិនមានចរន្តទឹកហូរនៅរដូវប្រាំង។

**តំបន់ទឹកសាធារណៈប្រភេទទី២៖** សំដៅដល់ប្រភពទឹកចំហមានជាអាទិ៍ សមុទ្រ ទន្លេ ពាម រួមបញ្ចូលទាំង ប្រឡាយទឹក ព្រែក ស្ទឹង ដែលមានចរន្តទឹកហូរនៅរដូវប្រាំង។

(-) ៖ ពុំមានកំណត់តម្លៃ

**(១)៖** ករណីការបញ្ចេញសំណល់រាវឬទឹកដែលប្រើប្រាស់សម្រាប់ការបញ្ចុះកម្ដៅម៉ាស៊ីនគ្រឿងចក្រដែលមានបរិមាណលើសពី៥០០០ម៉ែត្រគូបក្នុងមួយថ្ងៃ សីតុណ្ហភាពទឹកបញ្ចេញអាចអនុញ្ញាតក្នុងកម្រិត៥℃ (អង្សាសេ)លើសសីតុណ្ហភាពប្រភពទឹកទទួលនៅចំណុចចម្ងាយ៥០០ម៉ែត្រពីច្រាំងឬចំណុចបញ្ចេញ។



# តារាងឧបសម្ព័ន្ធ៣
## ប្រភពបំពុលដែលតម្រូវឱ្យមានការសុំអនុញ្ញាតពីក្រសួងបរិស្ថាន មុននឹងធ្វើការបញ្ចេញចោលឬដឹកសំណល់រាវទៅកាន់កន្លែងដទៃ

| ល.រ | ប្រភពបំពុល | កម្រិតទី | កូដ(ISIC) |
|---|---|---|---|
| ១ | ទីតាំងផលិតសម្លៀកបំពាក់ | ១ | 1410 |
| ២ | ទីតាំងផលិតផលិតផលនិងសម្ភារៈពីរោមសត្វ | | 1420 |
| ៣ | ទីតាំងផលិតសម្លៀកបំពាក់ដោយចាក់និងត្បាញ | | 1430 |
| ៤ | ទីតាំងផលិតផលិតផលនិងសម្ភារៈប្រើប្រាស់ផ្សេងៗចេញពីកៅស៊ូធម្មជាតិ ឬកៅស៊ូសំយោគ(ក្រៅពីកង់រថយន្ត) | ១ | 2219 |
| ៥ | ទីតាំងផលិតផលិតផលនិងសម្ភារៈពីសេរាមិចនិងព័រស៊ីឡែន | ១ | 2393 |
| ៦ | ទីតាំងផលិតស៊ីម៉ងត៍ កំបោរ និងម្នាងសិលា | | 2394 |
| ៧ | ទីតាំងផលិតលផិតផលសម្រាប់សំណង់ពីបេតុង | | 2395 |
| ៨ | ទីតាំងកាត់ថ្ម សំលៀង និងផលិតផលិតផល និងសម្ភារៈពីថ្ម | | 2396 |
| ៩ | ទីតាំងផលិតគ្រឿងសង្ហារឹម | ១ | 3100 |
| ១០ | ទីតាំងជួសជុលឧបករណ៍អុបទិកនិងឧបករណ៍អេឡិចត្រូនិក | ១ | 3313 |
| ១១ | ទីតាំងជួសជុលយានយន្តដឹកជញ្ជូន លើកលែងម៉ូតូ | | 3315 |
| ១២ | ទីតាំងដំឡើងម៉ាស៊ីននិងឧបករណ៍ឧស្សាហកម្ម | | 3320 |
| ១៣ | ទីតាំងផលិតខ្សែ ខ្សែពួរ និងសំណាញ់ | ១ | 1394 |
| ១៤ | ទីតាំងជីករ៉ែធម្មជាតិនិងខនិជ មានជាអាទិ៍រ៉ែផូស្វាត រ៉ែប៉ូតាស្យូម រ៉ែម៉ាញ៉េស្យូម | ២ | 0891 |
| ១៥ | ទីតាំងមន្ទីរពេទ្យនិងសម្ភព | ២ | 8610 |
| ១៦ | ទីតាំងចិញ្ចឹមគោនិងក្របី | ២ | 0141 |
| ១៧ | ទីតាំងចិញ្ចឹមសេះ | | 0142 |
| ១៨ | ទីតាំងចិញ្ចឹមចៀមនិងពពែ | | 0144 |
| ១៩ | ទីតាំងចិញ្ចឹមជ្រូក | | 0145 |
| ២០ | ទីតាំងចិញ្ចឹមមាន់និងទា | | 0146 |
| ២១ | ទីតាំងសត្តឃាត | ២ | - |
| ២២ | ទីតាំងបង្កកនិងកែច្នៃកៅស៊ូក្រែប | | - |
| ២៣ | ទីតាំងវារីវប្បកម្មទឹកប្រៃ | ២ | 0321 |
| ២៤ | ទីតាំងវារីវប្បកម្មទឹកសាប | | 0322 |
| ២៥ | ទីតាំងកែច្នៃនិងថែរក្សាសាច់ | ២ | 1010 |
| ២៦ | ទីតាំងកែច្នៃនិងថែរក្សាផលិតផលជលផល | | 1020 |
| ២៧ | ទីតាំងកែច្នៃនិងថែរក្សាបន្លែនិងផ្លែឈើគ្រប់ប្រភេទ | | 1030 |
| ២៨ | ទីតាំងផលិតប្រេងពីរុក្ខជាតិនិងខ្លាញ់សត្វ | | 1040 |

| | | | |
|---|---|---|---|
| ២៩ | ទីតាំងផលិតទឹកដោះនិងផលិតផលពីទឹកដោះ | | 1050 |
| ៣០ | ទីតាំងផលិតផលិតផលពីធញ្ញជាតិ | | 1061 |
| ៣១ | ទីតាំងផលិតម្សៅមីនិងផលិតផលពីម្សៅមី | | 1062 |
| ៣២ | ទីតាំងផលិតស្ករ | | 1072 |
| ៣៣ | ទីតាំងផលិតកាកាវនិងសូកូឡា | | 1073 |
| ៣៤ | ទីតាំងផលិតមីនិងគុយទាវ | | 1074 |
| ៣៥ | ទីតាំងផលិតផលិតផលអាហារ | | 1079 |
| ៣៦ | ទីតាំងផលិតចំណីសត្វ | | 1080 |
| ៣៧ | ទីតាំងផលិតស្រាឬអាល់កុល (កម្រិតអាល់កុលខ្ពស់) | ២ | 1101 |
| ៣៨ | ទីតាំងផលិតស្រាឬភេសជ្ជៈ (កម្រិតអាល់កុលទាប) | | 1102 |
| ៣៩ | ទីតាំងផលិតស្រាបៀរ | | 1103 |
| ៤០ | ទីតាំងផលិតភេសជ្ជៈនិងទឹកបរិសុទ្ធ | | 1104 |
| ៤១ | ទីតាំងផលិតសរសៃអំបោះ អំបោះហុង អំបោះឡែន | ២ | 1311 |
| ៤២ | ទីតាំងតម្បាញក្រណាត់ ក្រណាត់សូត្រ ស្បៃ | | 1312 |
| ៤៣ | ទីតាំងផលិតក្រណាត់ដោយចាក់និងប៉ាក់ | | 1391 |
| ៤៤ | ទីតាំងផលិតភួយ ក្រណាត់តង់ ក្រណាត់កម្រាល វាំងនន | | 1392 |
| ៤៥ | ទីតាំងផលិតកម្រាលព្រំ | | 1393 |
| ៤៦ | ទីតាំងផលិតក្តារបន្ទះ ឈើសន្លឹក ឈើកំណល់រថភ្លើង | ២ | 1621 |
| ៤៧ | ទីតាំងផលិតគ្រឿងបង្គុំសំណង់ពីឈើ | | 1622 |
| ៤៨ | ទីតាំងផលិតម្សៅក្រដាស ក្រដាស និងផលិតផលពីក្រដាស | ២ | 1701 |
| ៤៩ | ទីតាំងផលិតគ្រឿងអលង្ការកាឡែននិងខ្សែនាឡិកាពីលោហៈ | ២ | 3212 |
| ៥០ | ទីតាំងផលិតឧបករណ៍ភ្លេង | | 3220 |
| ៥១ | ទីតាំងផលិតសម្ភារៈកីឡា | | 3230 |
| ៥២ | ទីតាំងផលិតសម្ភារៈល្បែងនិងតុក្កតា | | 3240 |
| ៥៣ | ទីតាំងផលិតឧបករណ៍វេជ្ជសាស្ត្រ | | 3250 |
| ៥៤ | ទីតាំងជីករ៉ែ (បាសាល់ ក្រាហ្វីត ត្បូង ក្វាត និងរ៉ែស៊ីលីកាត) | ៣ | 0899 |
| ៥៥ | ទីតាំងបូមយកប្រេងឆៅ | ៣ | 0610 |
| ៥៦ | ទីតាំងដកយកឧស្ម័នធម្មជាតិ | | 0620 |
| ៥៧ | ទីតាំងវាយនភ័ណ្ឌសម្រេច មានជកពណ៌ឬជ្រលក់ពណ៌ | ៣ | 1313 |
| ៥៨ | ទីតាំងផលិត ចម្រាញ់ប្រេងកាត | ៣ | 1920 |
| ៥៩ | ទីតាំងផលិតសារធាតុគីមី | ៣ | 2011 |
| ៦០ | ទីតាំងផលិតជីនិងសមាសធាតុអាសូត | | 2012 |
| ៦១ | ទីតាំងផលិតប្លាស្ទិកនិងកៅស៊ូសំយោគ(ទំរង់បឋម) | | 2013 |
| ៦២ | ទីតាំងផលិតថ្នាំសម្លាប់សត្វល្អិតនិងផលិតផលគីមីកសិកម្ម | | 2021 |
| ៦៣ | ទីតាំងផលិតថ្នាំពណ៌ ថ្នាំលាប ថ្នាំប៉ូលា ថ្នាំបោះពុម្ព និងជីលែង | | 2022 |

| | | | |
|---|---|---|---|
| ៦៤ | ទីតាំងផលិតសាប៊ូដុំ សាប៊ូម្សៅ និងសាប៊ូទឹក | | 2023 |
| ៦៥ | ទីតាំងផលិតឱសថពីគីមីនិងពីរុក្ខជាតិ | ៣ | 2100 |
| ៦៦ | ទីតាំងផលិតសំបកកង់ បំពង់ជ័រពីកៅស៊ូ និងកែច្នៃឡើងវិញ | ៣ | 2211 |
| ៦៧ | ទីតាំងផលិតផលិតផលនិងសម្ភារៈពីប្លាស្ទិក | | 2220 |
| ៦៨ | ទីតាំងផលិតដែកនិងដែកថែប | ៣ | 2410 |
| ៦៩ | ទីតាំងផលិតលោហធាតុមានតម្លៃនិងលោហធាតុមិនមែនដែក | | 2420 |
| ៧០ | ទីតាំងផលិតផលិតផលពីលោហៈ | | 2431 |
| ៧១ | ទីតាំងស្លរំលោយលោហៈមិនមែនដែក | | 2432 |
| ៧២ | ទីតាំងផលិតផលិតផលសំណង់ពីលោហធាតុ | ៣ | 2511 |
| ៧៣ | ទីតាំងផលិតធុង អាង និងប្រអប់ដែលធ្វើពីលោហធាតុ | | 2512 |
| ៧៤ | ទីតាំងផលិតម៉ាស៊ីនចំហាយឬគ្រឿងបង្គុំ | | 2513 |
| ៧៥ | ទីតាំងដំ សង្កត់ និងរមូរដែកឬលោហធាតុ | | 2591 |
| ៧៦ | ទីតាំងស្លរំលោយ ចាក់ពុម្ព និងស្រោបលោហធាតុ | | 2592 |
| ៧៧ | ទីតាំងផលិតគ្រឿងបន្លាស់អេឡិចត្រូនិក | ៣ | 2610 |
| ៧៨ | ទីតាំងផលិតកុំព្យូទ័រនិងគ្រឿងបង្គុំ | | 2620 |
| ៧៩ | ទីតាំងផលិតឧបករណ៍ទំនាក់ទំនង | | 2630 |
| ៨០ | ទីតាំងផលិតគ្រឿងអេឡិចត្រូនិក | | 2640 |
| ៨១ | ទីតាំងផលិតឧបករណ៍វាស់ តេស្ត រុករក និងត្រួតពិនិត្យ | | 2651 |
| ៨២ | ទីតាំងផលិតនាឡិកាដៃនិងនាឡិកាប៉ោល | | 2652 |
| ៨៣ | ទីតាំងផលិតឧបករណ៍អុបទិក | | 2670 |
| ៨៤ | ទីតាំងផលិតឧបករណ៍ប្រព័ន្ធផ្សព្វផ្សាយអុបទិកនិងម៉ាញ៉េទិក | | 2680 |
| ៨៥ | ទីតាំងផលិតម៉ាស៊ីនភ្លើង ម៉ូទ័រ ឧបករណ៍បញ្ជានិងចែកចាយចរន្តអគ្គិសនី | ៣ | 2710 |
| ៨៦ | ទីតាំងផលិតថ្មពិល អាគុយ | | 2720 |
| ៨៧ | ទីតាំងផលិតខ្សែកាបអុបទិក | | 2731 |
| ៨៨ | ទីតាំងផលិតខ្សែភ្លើងនិងខ្សែកាបអគ្គិសនី | | 2732 |
| ៨៩ | ទីតាំងផលិតឧបករណ៍ខ្សែភ្លើង | | 2733 |
| ៩០ | ទីតាំងផលិតអំពូលភ្លើងគ្រប់ប្រភេទ | | 2740 |
| ៩១ | ទីតាំងផលិតប្រេងម៉ាស៊ីន | ៣ | 2811 |
| ៩២ | ទីតាំងផលិតម៉ាស៊ីនបូម ម៉ាស៊ីនបង្កើនសម្ពាធខ្យល់ ស្នប់ | | 2813 |
| ៩៣ | ទីតាំងផលិតចង្កូត ស្ពឺ ប្រអប់លេខ និងគ្រឿងបង្គុំ | | 2814 |
| ៩៤ | ទីតាំងផលិតឧបករណ៍សម្រាប់លើកដាក់ | | 2816 |
| ៩៥ | ទីតាំងផលិតគ្រឿងបរិក្ខារនិងសម្ភារៈការិយាល័យ | | 2817 |
| ៩៦ | ទីតាំងផលិតគ្រឿងយន្តកសិកម្ម | | 2821 |
| ៩៧ | ទីតាំងផលិតគ្រឿងយន្តសម្រាប់ការរុករករ៉ែនិងសំណង់ | | 2824 |
| ៩៨ | ទីតាំងផលិតគ្រឿងយន្តសម្រាប់កែច្នៃម្ហូបអាហារ ភេសជ្ជៈនិងថ្នាំជក់ | | 2825 |

| | | | |
|---|---|---|---|
| ៩៩ | ទីតាំងផលិតគ្រឿងយន្តសម្រាប់វាយនភ័ណ្ឌ | | 2826 |
| ១០០ | ទីតាំងផលិតយានយន្ត | ៣ | 2910 |
| ១០១ | ទីតាំងផលិតតួទោចក្រយានយន្ត យានយន្ត និងកន្ទុយសណ្តោង | | 2920 |
| ១០២ | ទីតាំងផលិតគ្រឿងបន្លាស់និងគ្រឿងបង្គុំយានយន្ត | | 2930 |
| ១០៣ | ទីតាំងសាងសង់នាវានិងសំណង់បណ្តែតទឹក | ៣ | 3011 |
| ១០៤ | ទីតាំងសាងសង់ទូកកម្សាន្តនិងកីឡា | | 3012 |
| ១០៥ | ទីតាំងផលិតទោចក្រយានយន្ត | | 3091 |
| ១០៦ | ទីតាំងផលិតកង់ | | 3092 |
| ១០៧ | ទីតាំងប្រព្រឹត្តកម្មសំណល់រាវ (តំបន់សេដ្ឋកិច្ចពិសេស សួនឧស្សាហកម្ម និងស្ថានីយប្រព្រឹត្តកម្មទឹកកខ្វក់រួម) | ៣ | 3700 |
| ១០៨ | ទីតាំងប្រព្រឹត្តកម្មនិងបោះចោលសំណល់មិនមែនគ្រោះថ្នាក់ | ៣ | 3821 |
| ១០៩ | ទីតាំងប្រព្រឹត្តកម្មនិងបោះចោលសំណល់គ្រោះថ្នាក់ | | 3822 |
| ១១០ | ទីតាំងសម្លាប់ស្បែកឬកែច្នៃរោមសត្វ | ៣ | - |
| ១១១ | ទីតាំងអាជីវកម្មរ៉ែមាស | | - |
| ១១២ | ទីតាំងផលិតអគ្គិសនី | | - |
| ១១៣ | ទីតាំងស្រាវជ្រាវ និងអភិវឌ្ឍការពិសោធន៍លើវិទ្យាសាស្ត្រធម្មជាតិ និងវិស្វកម្ម | ៣ | 7210 |

**កំណត់សម្គាល់៖**

(ISIC) ៖ ចំណាត់ថ្នាក់ឧស្សាហកម្មស្តង់ដាអន្តរជាតិ (International Standard Industry Classification)

(-) ៖ ពុំមានលេខកូដ

តារាងឧបសម្ព័ន្ធ៤

កម្រិតកំណត់ស្តង់ដាគុណភាពទឹកតំបន់ទឹកសាធារណៈ សម្រាប់អភិរក្សជីវៈចម្រុះនៅក្នុងទឹក

| លរ | ប៉ារ៉ាម៉ែត្រ | ខ្នាត | កម្រិតកំណត់ស្តង់ដា | | |
|---|---|---|---|---|---|
| | | | តំបន់ទឹកសាធារណៈប្រភេទទី១ | តំបន់ទឹកសាធារណៈប្រភេទទី២ | ទឹកសមុទ្រ |
| ១ | pH | | ៦,៥-៨,៥ | ៦,៥-៨,៥ | ៧,០-៨,៣ |
| ២ | កម្រិតរលាយអុកស៊ីសែន(DO) | mg/l | >៣ | >៤ | >៤ |
| ៣ | $BOD_5$ | mg/l | <៨ | <៦ | - |
| ៤ | $COD_{Mn}$ | mg/l | <១០ | <៨ | <៨[១] |
| ៥ | សារធាតុរឹងអណ្តែតក្នុងទឹក(TSS) | mg/l | <១០០ | <១០០ | <៨០ |
| ៦ | ជាតិអំបិល (Salinity) | mg/l | <១០០០ | <១០០០ | - |
| ៧ | នីត្រាត ($NO_3^{-1}$ as N) | mg/l | <២,៤ | <១,២ | <០,០៦ |
| ៨ | អាសូតសរុប (T-N) | mg/l | <៣ | <២ | <២ |
| ៩ | ផូស្វ័រសរុប (T-P) | mg/l | <០,២៥ | <០,១៥ | <០,០៩ |
| ១០ | ប្រេង ឬខ្លាញ់(Oil & grease) | mg/l | - | - | <០,១៤ |

**កំណត់សម្គាល់៖**

**តំបន់ទឹកសាធារណៈប្រភេទទី១៖** សំដៅដល់ប្រភពទឹកបិទមានជាអាទិ៍ បឹង ត្រពាំង ស្រះ ទីទំនាប រួមបញ្ចូលទាំងស្ទឹង ព្រែក អូរ និងប្រឡាយទឹកដែលមិនមានចរន្តទឹកហូរនៅរដូវប្រាំង។

**តំបន់ទឹកសាធារណៈប្រភេទទី២៖** សំដៅដល់ប្រភពទឹកចំហមានជាអាទិ៍ ទន្លេ ពាម រួមបញ្ចូលទាំងស្ទឹង ព្រែក អូរ និងប្រឡាយទឹកដែលមានចរន្តទឹកហូរនៅរដូវប្រាំង។

**(-) ៖** ពុំមានកំណត់តម្លៃ

[១]៖ សំដៅដល់តម្រូវការអុកស៊ីសែនតាមបែបប៉ូតាស្យូមពែម៉ង់កាណាតអាល់កាឡាំង $COD_{(OH)}$

## តារាងឧបសម្ព័ន្ធ៥

## កម្រិតកំណត់ស្តង់ដាគុណភាពទឹកតំបន់ទឹកសាធារណៈ សម្រាប់ការការពារសុខភាពសាធារណៈ

| លរ | ប៉ារ៉ាម៉ែត្រ | ខ្នាត | កម្រិតស្តង់ដា | កូដ (CAS No.) |
|---|---|---|---|---|
| ១ | កាបូនតេត្រាក្លរ ($CCl_4$) | µg/l | <៤ | (56-23-5) |
| ២ | អ៊ិចសាក្លរ៉ូបង់សែន ($C_6Cl_6$) | µg/l | <0,0៣ | (118-74-1) |
| ៣ | ដេដេតេ (DDT) | µg/l | <១ | (50-29-3) |
| ៤ | អង់ឌ្រីន ($C_{12}H_8Cl_6O$) | µg/l | <0,0១ | (72-20-8) |
| ៥ | ឌីអលឌ្រីន ($C_{12}H_8Cl_6O$) | µg/l | <0,0១ | (60-57-1) |
| ៦ | អេនឌ្រីន ($C_{10}H_{13}NO_3$) | µg/l | <0,00៥ | (309-00-2) |
| ៧ | អ៊ីសូឌ្រីន ($C_{12}H_8Cl_6$) | µg/l | <0,00៥ | (465-73-6) |
| ៨ | ពែក្លរ៉ូអេទីឡែន ($C_2Cl_4$) | µg/l | <១0 | (127-18-4) |
| ៩ | អ៊ិចសាក្លរ៉ូប៊ុយតាឌីអែន ($C_4Cl_6$) | µg/l | <0,0១ | (87-68-3) |
| ១0 | ក្លរ៉ូហ្វម ($CHCl_3$) | µg/l | <៣00 | (67-66-3) |
| ១១ | ១,២ ឌីក្លរ៉ូអេទីឡែន ($C_2H_2Cl_2$) | µg/l | <៤0 | (156-59-2) |
| ១២ | ទ្រីក្លរ៉ូអេទីឡែន ($C_2HCl_3$) | µg/l | <១0 | (79-01-6) |
| ១៣ | ១,២,៤ ទ្រីក្លរូបង់សែន($C_6H_3Cl_3$) | µg/l | <0,៤ | (120-82-1) |
| ១៤ | អ៊ិចសាក្លរ៉ូស៊ីក្លូអ៊ិចសែន($C_6H_6Cl_6$) | µg/l | <0,0៥ | (58-89-9) |
| ១៥ | បង់សែន ($C_6H_6$) | µg/l | <១0 | (71-43-2) |
| ១៦ | កាត់ម្យូម (Cd) | µg/l | <៣ | (7440-43-9) |
| ១៧ | បារ៉ាតសរុប (Hg) | µg/l | <0,៥ | (7439-97-6) |
| ១៨ | បារ៉ាតសរីរាង្គ ($CH_3Hg^+$ និង $C_6H_5Hg$) | µg/l | មិនអាចរកឃើញ | - |
| ១៩ | សំណ (Pb) | µg/l | <១0 | (7439-92-1) |
| ២0 | ក្រូមរ៉ាំឡង់៦ ($Cr^{+6}$) | µg/l | <៥0 | (18540-29-9) |
| ២១ | អាសេនិច (As) | µg/l | <១0 | (7440-38-2) |
| ២២ | សេលេញ៉ូម (Se) | µg/l | <១0 | (7782-49-2) |
| ២៣ | ប៉ូលីក្លរ៉ូ ប៊ីផេនីល (PCB) | µg/l | មិនអាចរកឃើញ | (1336-36-3) |
| ២៤ | ស្យានីតសរុប (CN) | µg/l | <៥ | (57-12-5) |
| ២៥ | ឌីក្លរ៉ូមេតាន ($CH_2Cl_2$) | µg/l | <២0 | (75-09-2) |
| ២៦ | កូលីហ្វមសរុប(Total coliform) | MPN /100mL | <១000 | - |

**កំណត់សម្គាល់៖**

កូដ CAS No. ៖ សំដៅដល់លេខកូដសារធាតុគីមី (Chemical Abstract Service Number)

(-) ៖ ពុំមានកំណត់លេខកូដ